ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

*ថ្ងៃអង្គារ ១៣កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥*
*រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១*

# សេចក្តីប្រកាសព័ត៌មាន

នៅរសៀលថ្ងៃអង្គារ ១៣កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឯកឧត្តម **ឈឿង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា/ក.អ.ក) បានទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម Christian Berger ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំព្រះរាជាណាចក្រកម្ពុជា តាមរយៈប្រព័ន្ធបញ្ចូនរូបភាព និងសម្លេង ។ គោលបំណងចម្បងនៃជំនួបនេះ គឺដើម្បីសម្តែងការគួរសម និងធ្វើការណែនាំសមាសភាពប្រធាន និងអនុប្រធានថ្មី និងពិភាក្សាលើអាទិភាពការងារនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ទ្វេភាគី ក៏ដូចជាផ្លាស់ប្តូរយោបល់លើទិដ្ឋភាពពាក់ព័ន្ធផ្សេងទៀត ។

ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ **ឈឿង យ៉ាណារ៉ា** បានសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** ព្រមទាំងបានអបអរសាទរចំពោះលោក Jost Kadel និងលោកស្រីបណ្ឌិត Angelika Stauder ដែលទើបត្រូវបានតែងតាំងដោយរដ្ឋាភិបាលអាល្លឺម៉ង់ ដើម្បីបំពេញបេសកកម្មនៅកម្ពុជា ។ ទន្ទឹមនឹងនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ** បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះរដ្ឋាភិបាលអាល្លឺម៉ង់ ដែលបានផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់វិស័យអាទិភាពធំៗចំនួន ៣ (វិស័យអភិវឌ្ឍន៍ជនបទ, សុខាភិបាល និងគាំពារសង្គម និងអភិបាលកិច្ច និងអន្តរវិស័យ) ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចអភិវឌ្ឍន៍នៅកម្ពុជា ជាពិសេសការផ្តល់ហិរញ្ញប្បទានឥតសំណងប្រមាណ ១៧ លានដុល្លារអាមេរិក ក្នុងការគាំទ្រដល់វិធានការឆ្លើយតបនឹងផលប៉ះពាល់នៃជំងឺកូវីដ-១៩ និងវិធានការស្តារសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ។ ជាមួយគ្នានេះ **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ** បានជម្រាបជូន **ឯកឧត្តមឯកអគ្គរដ្ឋទូត** និង**សហការី** ថា រាជរដ្ឋាភិបាលបានដាក់ចេញ "ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩" និងវិធានការចាំបាច់សំដៅបង្កើតឱ្យបានភាពស៊ាំសង្គម-សេដ្ឋកិច្ចនៅកម្ពុជា ដើម្បីឈានទៅបើកប្រទេសឡើងវិញជាបណ្តើរៗ តាមដំណាក់កាលជាមួយនឹងភាពប្រយ័ត្នប្រយែង និងការទទួលខុសត្រូវខ្ពស់តាមគន្លងប្រក្រតីភាពថ្មីនាពេលឆាប់ៗខាងមុខ ។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា និងវឌ្ឍនភាពសម្រេចបានក្នុងកិច្ចអភិវឌ្ឍន៍កម្ពុជា ។ **ឯកឧត្តមឯកអគ្គរដ្ឋទូត** ក៏បានណែនាំសហការីថ្មីទាំងពីររូប ដែលត្រូវបំពេញបេសកកម្មបន្តនៅកម្ពុជា ។ លោក Jost Kadel អនុប្រធានបេសកកម្ម និងជាប្រធានទទួលបន្ទុកផ្នែកកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងលោកស្រីបណ្ឌិត Angelika Stauder លេខាទី១ ទទួលបន្ទុកជាអនុប្រធានផ្នែកកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៃស្ថានទូតសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា បានសម្តែងនូវសេចក្តីសោមនស្សរីករាយដែលបានមកបំពេញបេសកកម្មនៅកម្ពុជា និងបានប្តេជ្ញាបន្តពង្រឹងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូឱ្យកាន់តែល្អប្រសើរ ។ **ឯកឧត្តមឯកអគ្គរដ្ឋទូត** និង**សហការី** ក៏បានជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ** អំពីការគ្រោងចុះមកសិក្សារបស់ក្រុមជំនាញការអាល្លឺម៉ង់ស្តីពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើសង្គម-សេដ្ឋកិច្ចក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជានាចុងឆ្នាំ២០២១ និងការត្រៀមរៀបចំកិច្ចពិគ្រោះយោបល់ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលគ្រោងនឹងប្រព្រឹត្តទៅក្នុងអំឡុងត្រីមាសទី ២ ឆ្នាំ ២០២២ ។ ទន្ទឹមនឹងនេះ **ភាគីទាំងពីរ** ក៏បានពិភាក្សា និងផ្លាស់ប្តូរយោបល់លើប្រធានបទពាក់ព័ន្ធ រួមមាន ÷ ផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើរចនាសម្ព័ន្ធសេដ្ឋកិច្ច, ការគ្រប់គ្រងលំហូរទឹកទន្លេមេគង្គ, ការប្រែប្រួលអាកាសធាតុ និងការរួមចំណែករបស់វិស័យឯកជនក្នុងកិច្ចអភិវឌ្ឍន៍ ។

មុននឹងបញ្ចប់ជំនួបនេះ **ភាគីទាំងពីរ** បានបង្ហាញជំហរយ៉ាងមុតមាំក្នុងការបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ក្នុងកិច្ចអភិវឌ្ឍន៍នៅកម្ពុជាប្រកបដោយចីរភាព និងបរិយាប័ន្ន ។ ឆ្លៀតក្នុងឱកាសនេះ ឯកឧត្តម **ឈៀង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការ គ.ជ.នា/ក.អ.ក បានថ្លែងអំណរគុណ និងជូនពរ ឯកឧត្តមឯកអគ្គរដ្ឋទូត Christian Berger, លោក Jost Kadel និងលោកស្រីបណ្ឌិត Angelika Stauder ទទួលបានជោគជ័យក្នុងការបំពេញបេសកកម្មនៅកម្ពុជា ៕